ប្រការ ៨ : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ហ៊្វឺរ វ៉ែលយូ (ខេមបូឌា) តិចជាយ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស៊ុយ សែម

***

## ៣- នីស្តីការរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០០០

### ប្រកាសលេខ ០២១ បន.ប្រក

### ស្តីពីសេវាស្ថានការ ដឹកនាំទូរស័ព្ទ ទូរសារ និងទូរព្រួ្ម ក្នុងតំបន់ក្រុងភ្នំពេញ និងតំបន់ខេត្ត-ក្រុង

***

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការ រៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ. ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ ១៩៩៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញ សេចក្តីសំរេចលេខ១៥៤ សសរ. ចុះថ្ងៃទី១១-១២-១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ
- បានឃើញកំណត់ហេតុអង្គប្រជុំនាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការកែប្រែតម្លៃសេវាទូរគមនាគមន៍
- យោងតាមស្មារតីអង្គប្រជុំថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០០០
- យោងតាមស្មារតីអង្គប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០០០

សំរេច

ប្រការ ១ : កំណត់តម្លៃស្ថាបនាការ ថែទាំទូរស័ព្ទ ទូរសារ និងទូរពុម្ព សំរាប់តំបន់ក្រុងភ្នំពេញ និង តំបន់ខេត្ត-ក្រុង ដូចមានចែងក្នុងតារាងភ្ជាប់មកជាមួយនេះ ។

ប្រការ ២ : សំភារៈស្ថាបនា និងបរិធានទូរស័ព្ទ ជាបន្ទុករាប់រង និងជាកម្មសិទ្ធិរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

ប្រការ ៣ : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកតាមតួនាទី ភារៈកិច្ចអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាព ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

សូ ឃុន

***

តារាងភ្ជាប់ប្រកាសលេខ ០២១ បទប្រក.

ចុះថ្ងៃទី ១១-០២-២០០០

### តារាងថ្លៃសេវា
### ស្ថាបនាការ ថែទាំទូរស័ព្ទ ទូរសារ ទូរលេខ
### ក្នុងតំបន់ក្រុងភ្នំពេញ និងតំបន់ខេត្ត-ក្រុង
### អនុវត្តចាប់ពីថ្ងៃទី ០១ ខែ មិនា ឆ្នាំ២០០០

***

| ក- ទូរស័ព្ទ ទូរសារ | I- តំបន់ក្រុងភ្នំពេញ | II- តំបន់ខេត្ត-ក្រុង |
|---|---|---|
| ១- ស្ថាបនា-ការទូរស័ព្ទ ទូរសារ | | |
| ១-១- ស្ថាបនា-ភ្ជាប់បណ្តាញថ្មី | | |
| គិតទាំងបរិធាន និងសម្ភារៈ............... | ១៥០$/គ្រឿង | ១០០$/គ្រឿង |
| ១-២- ប្តូរប្រព័ន្ធ ឬបណ្តាញ (Chang Over).... | ៤០$/គ្រឿង | ២០$/គ្រឿង |
| ១-៣- តម្លើងបរិធានភ្ជាប់បំបែក (Parallel)(1).... | ៣០$/គ្រឿង | ៣០$/គ្រឿង |
| ១-៤- តម្លើងម៉ាស៊ីនទូរសារ (ម៉ាស៊ីនឯកជន).... | ២០$/គ្រឿង | ២០$/គ្រឿង |
| ១-៥- ផ្ទេរទីកន្លែង (ក្នុងអាគារ).................... | ១០$/គ្រឿង | ១០$/គ្រឿង |
| ១-៦- ផ្ទេរអាស័យដ្ឋាន............................. | ៤០$/គ្រឿង | ២០$/គ្រឿង |
| ២- ការផ្តល់លេខទូរស័ព្ទ (២)(៤)(៦) | | |
| ២-១- ផ្ទេរកម្មសិទ្ធិ "កាត់ឈ្មោះ" ............... | ៦០$/លេខ | ៥០$/លេខ |
| ២-២- ផ្តល់លេខទូរស័ព្ទប្រភេទ "Reversed Signal" | ៣០$/លេខ | ៣០$/លេខ |
| ២-៣- ផ្តល់លេខទូរស័ព្ទប្រភេទ "Hunting Group" | ២០$/លេខ | ២០$/លេខ |
| ២-៤- ប្តូរលេខទូរស័ព្ទ ......................... | ៤០$/លេខ | ២០$/លេខ |
| ៣- ប្រាក់ធានាតំកល់ទុកសំរាប់ការប្រើប្រាស់ (បង់មុន) [៣] | | |
| ៣-១- សេវាក្នុងប្រទេស ................ | ៦០$/លេខ | គ្មាន |
| ៣-២- សេវាក្នុងប្រទេស និងអន្តរជាតិ ............ | ២០០$/លេខ | ២០០$/លេខ |

៤- ការស្ថាបនាប្រើប្រាស់បណ្តោះអាសន្ន រយៈបី (៣) ខែខ្លីបំផុត

អនុវត្តតម្លៃគ្រប់ចំណុច ១.១, ២.២, ២.៣ ស្មើ ៥០ភាគរយ និងចំណុច ៣ ខាងលើ ។

ខ- ទូរលេខ (TELEX) (៤) : ប្រើប្រាស់មជ្ឈមណ្ឌលនៅក្រុងហុងកុង

★★★

តារាងភ្ជាប់ប្រកាសលេខ ០២១ បទប្រក.

ចុះថ្ងៃទី១១ ០០២-២០០០

១- <u>តំបន់ក្រុងភ្នំពេញ</u>

១-១- ស្ពានគោការទូរពុម្ព តម្លៃម៉ោភ្ជាប់ (ម៉ាស៊ីនឯកជន) ............... ៣៥០$/គ្រឿង

១-២- តម្លើងម៉ាស៊ីនទូរពុម្ព (ម៉ាស៊ីនឯកជន) ............................ ៣០$/គ្រឿង

២- <u>តំបន់ខេត្ត-ក្រុង</u> អនុវត្តតំលៃដោយសារពេលការ (Estimate) តាមខេត្ត-ក្រុងនិមួយៗ

២-១- តំលៃបរិបថចំណុះ 2.4 Kbps (4w)

២-២- តំលៃម៉ោភ្ជាប់ក្នុងក្រុង (ម៉ាស៊ីនឯកជន) .............................. ៣៥០$/គ្រឿង

២-៣- តម្លើងម៉ាស៊ីនទូរពុម្ព (ម៉ាស៊ីនឯកជន)

៣- <u>ប្រាក់ធានាតំកល់ទុកសំរាប់ការប្រើប្រាស់</u> .......................... ២០០$/គ្រឿង

គ- <u>ថ្លៃជួលសេវាប្រចាំខែ</u>

១- <u>ការប្រើប្រាស់ទូរស័ព្ទ-ទូរសារ</u>

| | តំបន់ក្រុងភ្នំពេញ | តំបន់ខេត្ត-ក្រុង |
|---|---|---|
| ១-១- ជួលជាវនិងថែទាំបណ្តាញ | ១៣$/លេខ | ១០$/លេខ |
| ១-២- បរិធានភ្ជាប់បំបែក | ២$/លេខ | ២$/លេខ |
| ១-៣- លេខទូរស័ព្ទប្រភេទ “Reversed signal” | ៣$/លេខ | ៣$/លេខ |

២- <u>ការប្រើប្រាស់ទូរពុម្ព</u>

២-១- ជួលជាវនិងថែទាំបណ្តាញក្រៅប្រទេស ៥៥$/លេខ

២-២- ជួលជាវនិងថែទាំបណ្តាញក្នុងក្រុង ២៦$/លេខ

២-៣- ជួលជាវនិងថែទាំបណ្តាញក្នុងប្រទេស ............. ៣៦$/លេខ

<u>៣-ការផ្អាកប្រើប្រាស់បណ្តោះអាសន្ន សេវាទូរស័ព្ទនិងសេវាទូរពុម្ព</u>

៣-១- អនុញ្ញាតការផ្អាកបណ្តោះអាសន្នត្រឹមរយៈ ៣ (បី) ខែ គិតថ្លៃ ៥០% នៃថ្លៃជួលជាវប្រចាំខែ។

៣-២- ការបង់ថ្លៃជួលជាវសេវាដែលបានប្រើប្រាស់មិនពេញខែ ត្រូវបានគិតតាមចំនួនថ្ងៃប្រើប្រាស់ ក្នុងតំលៃ ១/៣០ ភាគ នៃថ្លៃជួលជាវប្រចាំខែ ។

<u>៤-ការផ្តល់វិក្កយបត្រលំអិតលើការប្រើប្រាស់សេវា(៧)</u>

-វិក្កយបត្រលំអិត សន្ទនាការទូរស័ព្ទក្នុងក្រុងប្រចាំខែ ............. ៣$ / ច្បាប់

★★★

<u>៥ លក្ខខណ្ឌនៃការផ្តល់ផ្គត់សេវា :</u>

៥-១- ការស្នាបនា-តម្លើងបរិធានភ្ជាប់បំបែក (Parallel) ត្រូវបានអនុញ្ញាតតាមលក្ខខណ្ឌបច្ចេកទេសបានមួយគ្រឿងក្នុងអាគារតែមួយ សំភារៈផ្គត់ផ្គង់ដោយក្រសួង ។

៥-២- លេខទូរស័ព្ទត្រូវបានផ្គត់ផ្គង់ជូនជាកម្មសិទ្ធឯកជន ពុំអាចបរិគាគារណៈដោយគ្មានច្បាប់អនុញ្ញាត ។

៥-៣- ប្រាក់ធានាតំកល់ទុកត្រូវបានបង់ក្នុងគ្រាស្ថាបនាការ និងត្រូវដកបង្វែរជូនអតិថិជនវិញ ល្អិតណាបានសុំបញ្ឈប់ការប្រើប្រាស់សេវាជាស្ថាពរ និងបានធ្វើការទូទាត់ថ្លៃសេវាគ្រប់ចំនួន ។

៥-៤- ភ្នាក់ងារមានច្បាប់លក់លេខទូរស័ព្ទនៅរាជធានីភ្នំពេញ អាចគិតយកថ្លៃ ៣០ ដុល្លារ (៣០$) និងនៅខេត្តមួយគ្រឿង ១០ ដុល្លារ (១០$) បន្ថែមលើថ្លៃស្ថាបនាការគ្រាដំបូង (Installation Fees) ដែលរដ្ឋកំណត់ សំរាប់ការងារសិក្សាទីផ្សារ និងផ្សព្វផ្សាយពាណិជ្ជកម្ម ។

៥-៥- ការស្ថាបនាប្រើប្រាស់សេវាទូរពុម្ព (Telex) ជាបណ្តោះអាសន្នពុំត្រូវបានអនុញ្ញាត ។

៥-៦- ការផ្លាស់ប្តូរលេខទូរស័ព្ទ ត្រូវធ្វើការទូទាត់បំណុលថ្លៃសេវាជាមុន ។

៥-៧- វិក្កយបត្រប្រើប្រាស់សេវាត្រូវបានចេញជូនរៀងរាល់ដំណាច់ខែ នៃប្រតិទិន មានទំរង់ជាតារាងសរុបលើប្រភេទសន្ទនាការ ។ អតិថិជនអាចសុំអោយផ្តល់វិក្កយប័ត្រតាមករណីពិសេសដោយត្រូវបង់ថ្លៃបន្ថែម ។

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ១៩៩៩

## ប្រកាសលេខ ០២២ បន.ប្រក

## ស្តីពីថ្លៃសេវាទូរគមនាគមន៍

## និងរូបភាពទូរទស្សន៍ ប្រើប្រាស់ក្នុងប្រទេស និងអន្តរជាតិ

***

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការ រៀបចំ និងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី